N° 3 - Kambujasuriya -

INDOCHINE FRANÇAISE
RÉGIE
១១
DÉPÔT LÉGAL

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ២៦ ខែមីនា លេខ ៣
Mars
ព.ស. ២៤៩៦ – គ.ស. ១៩៥៤

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

| វែ្នកសាសនា | | ទំព័រ |
|---|---|---|
| — សុខកថា ................. | ព្រះមហា សុខ-វ៉ន់ ....... | ១៦៣ |
| — វម្មិកបញ្ហា ................. | ព្រះមហា ប័ន្ធ-ហុង ...... | ១៧២ |

វែ្នកអក្សរសាស្ត្រ

| | | |
|---|---|---|
| — រឿងព្រេងបូននិទាន ........... | ឃុនបណ្ណារ័ក្ស ប៊ូ-ប៊ូ ...... | ១៨២ |
| — ការបណ្ដុះនិស្ស័យ (តមក) ........ | ព្រះមហាឧត្ដមវិជ្ជា ប៊ុង-ប៉ម ... | ១៨៩ |
| — រឿងសាមកុក (តមក) ........... | ឧកញ៉ា នូ-កន ......... | ១៩៨ |
| — នាលះនិងទមយន្តី (តមក) ........ | អ្នកស្រី ស្រ៊ុន-សាវីយ៉ាន់ .... | ២១០ |
| — ដំណើរអស្ចារ្យនៃលោកភ៉ាស្វប៉ីយូ យេ (តមក) .................. | លោកភ៉ុយ-ប៊ុក .......... | ២១៩ |
| — ដំណឹងតាមខ្យល់ក្នុងកន្តារៈ (តមក) .... | លោកផេង-ជ្រើវ .......... | ២២៥ |

កំណត់ទិនប្រវត្តិការណ៍

| | | |
|---|---|---|
| — សុន្ទរកថាថ្លែងក្នុងពិធីអនុសំវច្ឆរៈមហាសន្និបាតនៃមន្ត្រីសង្ឃលើកទី ១០ ........ | ឯកឧត្ដម សម-ញាណ..... | ២៣៥ |

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២០០រ.០០

សុខគាថា

# ព្រះមហា សុខ-វង់ និស្សិតសាលាបាលីជាន់ខ្ពស់

រៀបរៀង.

---

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការព្រះភគវន្តមុនីអរហំសម្មាសម្ពុទ្ធ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃដោយសេចក្ដីគោរព) ។

លំដាប់នេះ អាត្មាភាពនឹងសំដែងអំពីកំណើតនៃសេចក្ដីសុខ ជាសង្ខេបតាមសមគួរដល់កាលវេលា ដូចមានសេចក្ដីតទៅនេះ ។

សុខោ ពុទ្ធានមុប្បាទោ "ការកើតឡើង នៃព្រះពុទ្ធទាំងឡាយ ជាហេតុនាំឲ្យកើតសេចក្ដីសុខ" ។

អធិប្បាយថា: ក្នុងកាលដែលមានព្រះសម្មាសម្ពុទ្ធបានត្រាស់ដឹងឡើង, សត្វមានចំនួនច្រើននឹងរាប់មិនអស់ តែងបានជួបប្រទះនូវប្រយោជន៍នឹងសេចក្ដីសុខស្ងប់ដ៏ក្រៃលែង ។ ព្រោះព្រះសព្វញ្ញុពុទ្ធទ្រង់ឧបត្តិឡើង ទ្រង់ប្រកបដោយសិរីសម្បត្តិដ៏ខ្ពង់ខ្ពស់គួរស្ញើច ជាទីបូជារបស់ពួកជនហើយបរិបូណ៌ដោយចំណេះវិជ្ជាគ្រប់យ៉ាង ព្រមទាំងមានព្រះទ័យពេញប្រៀបដោយសេចក្ដីករុណា អាណិតអាសូរពួកសត្វទៅក្នុងត្រៃភព

ឥតពើសមុទ ។ ដោយពិត, ព្រះបរមគ្រូដែលទ្រង់បានជួបប្រទះនឹង សេចក្ដីសុខក្សេមខ្ពង់ខ្ពស់ផុតចំណោមមនុស្ស ដោយគោត្រត្រកូលកជ-សម្បត្តិជាដើម ក៏ព្រោះតែបុណ្យ សេចក្ដីល្អដែលទ្រង់បានកសាង សន្សំទុកជាលំដាប់ជាតិៗមក ។

ព្រះលោកនាថប្រកបដោយព្រះមហាករុណាធិគុណ ទោះបី ព្រះអង្គបានសេចក្ដីសុខស្រួលដូចម្ដេច ក៏មិនទម្រន់ឲ្យលក់ដក់នឹងជាប់ ព្រះទ័យឲ្យទាល់តែលង់ចាំងគំនិតដល់ភ្លេចនឹកមិនឃើញ នូវការសុខទុក្ខ របស់ពពួកសត្វដែលលិចលង់ក្នុងលោកសន្និវាសនេះទេ, ព្រះអង្គមិនព្រម ទទួលសោយសេចក្ដីសុខចំរើនជាផលសំណាងដែលបានមកតាំងនៅសឹប់ ក្នុងគណ្ដាប់ព្រះហស្ដរបស់ព្រះអង្គតែមួយព្រះអង្គប៉ុណ្ណោះទេ ទ្រង់ស៊ូលះ បង់ប្រយោជន៍ទាំងនោះចោលស្រឡះមិននឹកនា ចំប្រឹងបំពេញព្យាយាម ទាល់តែបានសម្រេចប្រាជ្ញាពោធិញ្ញាណលើសគេបល្ល័ង្ក ព្រះអង្គបានទីជា សត្ថានាយកៈអ្នកដឹកនាំប្រោសស្រង់សត្វទូទៅក្នុងលោក ឲ្យផុតពីសេចក្ដី ទុក្ខលំបាកមានកើត, ចាស់, ឈឺ, ស្លាប់ជាដើម (ដូចជាសំពៅធំ) ។

ចាប់ដើមតាំងពីត្រឹមឆ្នាំដែលទ្រង់បានត្រាស់ដឹងមក ព្រះអរហំ សម្មាសម្ពុទ្ធ ស្ដេចយាងទៅប្រកាសសាសនាប្រទានទូន្មានពាក្យប្រៀន ប្រដៅណែនាំពពួកសត្វមានមនុស្សនិងទេវតាជាដើម, ចំប្រឹងព្យាយាម សំដែងធម៌បំភ្លឺពន្យល់ប្រាប់គុណ, ទោស, ខុស, ត្រូវ ឲ្យសត្វយល់ឃើញ

ពិតៗ ឥតរួញរានឹងសេចក្ដីនឿយព្រួយព្រះកាយពលក្នុងការប្រកាសប្រាប់ប្រយោជន៍របស់សត្វទាំងនោះឡើយ ។

ព្រះអង្គទ្រង់ប្រឹងបំពេញពុទ្ធកិច្ចគ្រប់គ្រាន់មិនមានបន្ទោះសមស័ក្ដិ ព្រះអង្គជា សត្ថនាយកៈ អ្នកដឹកនាំស្រោចស្រង់ជាទីពឹងពាក់ពំនាក់ការស្រ័យនៃសត្វក្នុងត្រៃលោកមែនៗ ទាំងមានព្រះឥរិយាបថស្រគត់ស្រគំសមរម្យ មានព្រះអធ្យាស្រ័យដ៏ទន់ភ្លន់ស្មោះស្មើ ស្ទុះត្រង់ទៅរកសត្វទូទៅ, គួរឲ្យមនុស្សទេវតានឹងសត្វគ្រប់ថ្នាក់ មានសេចក្ដីសង្ឃឹមកក់ក្ដៅចូលទៅជ្រកកោនក្រោមម្លប់ពោធិសម្ភារ បានសម្រេចសន្តិសុខតាមប្រាថ្នា; ព្រះអង្គមានទំនងគួរឲ្យសត្វក្នុងសកលលោកគោរពក្រាបសំពះយកតម្រាប់តាម ដោយសេចក្ដីពេញចិត្តមិនបាច់បង្ខំ ។

ព្រះពុទ្ធគុណដែលរៀបរាប់មកខាងលើនេះ បើពោលបំព្រួញឲ្យខ្លីងាយចំណាំជាងនោះមកទៀត ថា ព្រះអរហំសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់ទ្រង់មានព្រះទ័យស្អាត មិនប្រឡាក់ដោយបាបសេចក្ដីអាក្រក់ណាមួយដូច្នេះហៅថា វិសុទ្ធិគុណ ។ ទ្រង់ខំប្រឹងបំពេញប្រយោជន៍ឲ្យសត្វបានទទួលសេចក្ដីសុខតាមគតិលោកគតិធម៌ពល់គ្នា សមគួរដល់ក័ព្វសំណាងសត្វ មិនលាក់បិទប្រយោជន៍ទុកសម្ងំសោយសេចក្ដីសុខស្រួលតែមួយព្រះអង្គឡើយ ដូច្នេះហៅថា ករុណាគុណ ។ ទ្រង់មាន

•បាយដ៏ប្រពៃក្នុងការទូន្មានសត្វ ធ្វើសេចក្តីជ្រៅឲ្យកក់ កំបាំងឲ្យឆ្ងាយ យល់ ឆ្ងាយគិតជាដើម ដូច្នេះហៅថា បញ្ញាគុណ ។

ដោយហេតុនេះទើបប្រាកដថា ព្រះពុទ្ធគ្រប់ព្រះអង្គបានត្រាស់ដឹង ឡើងក្នុងលោក ជាហេតុនាំឲ្យបានសេចក្តីសុខ (ដល់ពួកសត្វក្នុងត្រៃគត) ។ សេចក្តីដែលសំដែងមកនេះជាគុណដែលមានក្នុងព្រះអង្គ ។

ស្វាក្ខាតោ ភគវតា ធម្មោ ធម៌ដែលព្រះសម្ពុទ្ធសំដែងដោយប្រពៃ មានគុណអាចប្រោសស្រង់សត្វលោកដែលពេញចិត្តកាន់តាម ឲ្យផុតអំពីទុក្ខទោស បានសេចក្តីសុខស្រួលឃើញជាក់ច្បាស់ចំពោះមុខភ្លាមៗ តាមថ្នាក់តាមជាន់ឥតបង្អង់ចាំកាលវេលា ។ ធម្មោ សុចិណ្ណោ សុខមាវហាតិ ធម៌ដែលសត្វបានរក្សាទុកត្រឹមត្រូវ នឹងផ្តល់សេចក្តីសុខមកឲ្យវិញពុំខាន ។

អធិប្បាយថា: អំពើល្អហៅថាធម៌, អ្នកប្រព្រឹត្តត្រឹមត្រូវតាមធម៌ ឈ្មោះថាបានរក្សាធម៌ទុកដោយប្រពៃ នឹងត្រូវបានផលជាសុខ; អ្នកមិនកាន់តាមធម៌នឹងត្រូវបានផលជាទុក្ខ ។ រួមព្រះធម៌ទាំង ៨៤០០០ ធម្មក្ខន្ធ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងហៅថាពុទ្ធសាសនា ។

សាធុជន ដែលពេញចិត្តគាប់អធ្យាស្រ័យក៏ចង់បានប្រយោជន៍ សេចក្តីសុខសេចក្តីចំរើនត្រឹមតែក្នុងលោកនេះក៏គួរតែបង្អោនចិត្ត ចូលមក

កាន់ព្រះពុទ្ធសាសនាកុំខាន ព្រោះព្រះពុទ្ធសាសនានេះ អ្នកប្រាជ្ញជាន់ខ្ពស់ក្នុងលោក បានពិនិត្យឃើញពិតថា ជាសាសនាមានអានុភាពអាចធ្វើលោកឲ្យស្ងប់, ទាំងញុំាងមនុស្សសត្វដែលទន់ទាប់ថោកថយឲ្យខ្ពង់ខ្ពស់ថ្លៃថ្នូរ, បើថ្លៃថ្នូរស្រាប់ ឲ្យរឹងរឹតតែវិសេសក្រៃលែងឡើងទៀត ៗ សេចក្ដីដែលពណ៌នាមកនេះ ត្រង់តាមគោលដើមនៃពុទ្ធបំណងពិត, ព្រោះព្រះអង្គដែលទ្រង់ប្រឹងព្យាយាមសំដែងច្បាប់ប្រាប់ពន្យល់មិនខ្វាចនឿយហត់ទាំងម៉្លេះ ដោយទ្រង់មានព្រះទ័យករុណាចង់ដោះស្រាយពួកសត្វដែលជាប់ចំណងនៃសេចក្ដីទុក្ខលំបាកមានជាតិ, ជរា, ព្យាធិ, មរណៈជាដើម ឲ្យរួចចាកទុក្ខបានសេចក្ដីសុខស្កប់ស្កល់ប៉ុណ្ណោះ ៗ

ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ថា ពួកមនុស្សសត្វកើតមកពេញទាំងសកលលោក សុទ្ធសឹងតែប្រាថ្នាសេចក្ដីខ្ពង់ខ្ពស់ថ្លៃថ្នូគ្រប់ ៗ រូប, ដែលបែរជាបានសេចក្ដីអាប់ឱនទន់ទាប មិនសមដូចបំណងស្មើគ្នាទៅវិញនោះ បណ្ដាលមកពីហេតុច្រើនយ៉ាងណាស់, ខ្លះកើតឡើងដោយសេចក្ដីទន់ទាបក្រីក្រល្ងង់ខ្លៅស្រាប់មកអំពីកំណើតក៏មាន ព្រោះផលបុព្វកិច, ខ្លះកើតមកបានជួបប្រទះនឹងសេចក្ដីចំរើនសម្បូណ៌សម្បត្តិគ្រប់គ្រាន់ស្រាប់ពីកំណើត តែធ្វេសភ្លេចគិតបណ្ដោយចិត្តឲ្យទៅប្រព្រឹត្តអាក្រក់ទាស់ទំនង ពាន់ទៅលើអំពើមិនមែនជាធម៌ បានសេចក្ដីថ្លស់

ដោយធ្លាក់ខ្លួនជាអ្នកទន់ទាបអាប់ឱនខ្ចួចទៅវិញក៏មាន, ខ្លះទប់ខ្លួនឲ្យនៅត្រឹមតែស្មើៗ មិនទាបមិនខ្ពស់ក៏មាន, តាមសមគួរដល់អំពើដែលសត្វបានធ្វើរៀងៗខ្លួន ; ដូចពុទ្ធភាសិតថា សត្តេ កម្មំ វិភជ្ជតិ កម្មគឺអំពើដែលសត្វធ្វើទុកមកអំពីជាតិមុន ឬជាតិនេះជាមេចំណែកចែកឲ្យសត្វបានសុខបានទុក្ខផ្សេងៗគ្នា មិនមែនអ្វីផ្សេងក្រៅពីអំពើរបស់ខ្លួននោះចែកឲ្យឡើយ ។

ឯអំពើអាក្រក់ នាំមនុស្សឲ្យវិនាសបានសេចក្ដីទុក្ខលំបាកទាំងលោកនេះនិងលោកខាងមុខនោះ គឺ:

អបាយមុខ (ហេតុដែលនាំឲ្យវិនាសសេចក្ដីចំរើន) ៤ យ៉ាងគឺ:

១—ឥត្ថីធុត្ត: អ្នកដោកចិត្តជក់និងមាតុគ្រាម មិនមានចិត្តសន្ដោសត្រឹមតែភរិយា - ស្វាមីរបស់ផងខ្លួន

២— សុរាធុត្ត: អ្នកសេពគ្រឿងស្រវឹង

៣— អក្ខធុត្ត: អ្នកលេងល្បែងភ្នាល់

៤— បាបមិត្ត: អ្នកគប់រកមនុស្សអន្ធពាល អាក្រក់ជាមិត្រ ។

ហេតុទាំង ៤ នេះសុទ្ធសឹងតែជាអំពើអាក្រក់ អាចនាំឲ្យប្រទេសជាតិមាតុភូមិ ភោគសម្បត្តិនិងចរិយាស្រុកស្រុតចុះថោកទាបនាំឲ្យវិនាសបង់ដោយខូចបង់ប្រយោជន៍សេចក្ដីសុខចំរើន របស់មនុស្សក្នុងសកលលោក

ដាក់ស្នែងភ្លាមៗ មិនបាច់ពោលថ្វីទៅលោកខាងមុខនោះឡើយ ។ មែនពិត, អំពើទាំងនេះ បើសត្វទំប្រឹងប្រព្រឹត្តជាប់មិនលែង លោកពោលថាទុកដូចជាគប់ភ្លើងយ៉ាងធំ មកដុតកោលកំទេចបំផ្លាញគោលសម្បត្តិ ចំណេះវិជ្ជា, ចរិយា, មារយាទ, ជាតិកំណើត, និងសន្តិសុខ ដ៏រុងរឿងរបស់ខ្លួនឲ្យខ្ទេចក្រិនខ្ទួច លែងលូតលាស់ដុះចំរើនឡើងទៀត រួចបេះតែរេចរិលទៅជានិច្ច ឈ្មោះថាមនុស្សផ្ញួញទុក្ខ ។

បុគ្គលគួរកុំប្រព្រឹត្តអំពើទាំងនេះឲ្យសោះ កាលបើយើងវៀរចាកអំពើទាំងនេះរួចស្រឡះហើយ ឈ្មោះថាបានប្រព្រឹត្តធម៌ រក្សាធម៌ទុកដោយប្រពៃ នឹងបានផលជាសុខច្រើនប្រការ; បើពោលដោយសង្ខេបវិញ គឺ:

១ – សុខព្រោះមានចិត្តស្រះស្រួលស្មោះស្មើទៅរកស្វាមីភរិយា ដោយមិនជាប់ចិត្តនឹងបុរស-ស្ត្រីឯទៀត ;

២ – សុខព្រោះមានសំដីបសាជាប្រក្រតី មិននិយាយឡេះឡោះកកៃកកររករឿងឈ្លោះ មិនខូចបង់ប្រាក់កាស ដោយហេតុមិនសេពសុរា;

៣ – សុខព្រោះបានធ្វើការងារចំរើន រៀនវិជ្ជាចេះចាំមិនភ័យនឹងអ្នកកផការចាប់ចង ឃុំឃាំងលក់ខ្នៃ ដោយហេតុមិនលេងល្បែងភ្នាល់;

៤ – សុខព្រោះចិត្តស្លូតត្រង់ មិនចេះធ្វើអំពើអាក្រក់ ដោយហេតុមិនសេពគប់គេជនពាល ។

ឯការគប់រកជនអន្ធពាល នាំឲ្យចេះចំណេះអាក្រក់ ព្រោះមនុស្សពាលមិនដែលមានសមត្ថភាព ខាងឯនាំឲ្យប្រព្រឹត្តល្អទេ មិនស្គាល់ហេតុនាំឲ្យបានសុខ ស្តាប់ពាក្យគ្រូមិនសូវបាន, បើអ្នកដែលទៅសេពគប់មិនចេះលេងស្រី នាំឲ្យចេះលេងស្រី, មិនចេះសេពសុក នាំឲ្យចេះសេពសុក, មិនចេះលេងល្បែងភ្នាល់ នាំឲ្យចេះល្បែងភ្នាល់, រហូតដល់ទៅនាំឲ្យចេះដើរលេងយប់, បោកប្រាស់បំបាត់ប្រវ័ញ្ចគេ ធ្លាក់ដល់ចេះលួចប្លន់កាប់សម្លាប់គេក៏សឹងមាន; ត្រូវនឹងពុទ្ធភាសិតថា អសេវនា ច ពាលានំ ការមិនគប់រកពួកជនពាល ចាត់ជាមង្គលដ៏ប្រសើរ ។

អ្នកដែលវៀរចាកអំពើអាក្រក់ ដូចបានពោលមកហើយនេះ ទុកដូចជាអ្នកបានបណ្តុះប្រយោជន៍ដ៏ធំទូលាយចំពោះខ្លួនផង ទុកសម្រាប់ប្រទេសជាតិមាតុភូមិ ឲ្យដើរលឿនទៅកាន់វឌ្ឍនធម៌ខាងអនាគតផង ។ សេចក្តីសុខទុក្ខទាំងនេះកើតមកអំពីកម្មផ្ទាល់ខ្លួនពិត ៗ ការលះបង់អបាយមុខមានប្រយោជន៍ដ៏ធំទូលាយក្រៃពេក ។ ដែលសំដែងមកនេះជាសេចក្តីសង្ខេប ។

មិនត្រឹមតែប៉ុណ្ណោះដែលហៅថាសាសនាបរិសុទ្ធនោះ គឺជាសាសនាអាចប្រោសលោកឲ្យលឿនទៅកាន់សេចក្តីចំរើន ទប់សត្វមិនឲ្យធ្លាក់ទៅកាន់ទីថោកទាបមាននរកជាដើម ឲ្យលោកបានសេចក្តីសុខស្ងប់ ទាំង

ធ្វើឲ្យអ្នកជឿស្តាប់កាន់តាម បានប្រទះប្រយោជន៍សេចក្តីចំរើនដោយ គោតសម្ព័ទបញ្ញាសម្ព័ទ គេរួចឈ្មោះយសសក្តិតាមសមគួរ មិនមែន សំដែងប្រាប់ឲ្យមនុស្សសត្វ ដេកទម្រន់ចាំសំណាងពីព្រេងនាយតែម្យ៉ាង ទេ ដូចពុទ្ធភាសិតថា សុស្សូសំ លភតេ បញ្ញំ អ្នកមានប្រាជ្ញាចេះ ចំណេះវិជ្ជាគ្រប់យ៉ាងបានមកពីប្រឹងរៀនស្តាប់ទន្ទេញ មិនធ្វេសប្រហែស ក្នុងការរៀនសូត្រ ឧដ្ឋាតា វិន្ទតេ ធនំ អ្នកមានទ្រព្យគ្រប់គ្រាន់ មកពីរវៀសរវៃប្រឹងរកប្រឹងធ្វើមិនខ្ជិល ៗ សេចក្តីដែលសំដែងមកប៉ុណ្ណោះ តាមលំអានព្រះពុទ្ធសាសនា ជាសាសនាប្រាប់ផ្លូវប្រតិបត្តិយ៉ាងកណ្តាល មិនឲ្យសត្វកាន់ឆាកធ្លាក់ទៅលើផ្លូវប្រតិបត្តិធ្ងន់ដែលហៅថា អត្ត បដិ បទា សេចក្តីប្រតិបត្តិដ៏លាមក ឬអមទាំងនោះឡើយ មានចំនួនឲ្យពួក ពុទ្ធបរិស័ទ នាំគ្នាកាន់តាមសេចក្តីពេញចិត្តឥតបង្ខិតបង្ខំ ៗ

ព្រោះហេតុនោះ ទើបអធិប្បាយថាជាសាសនា ស្អាងលោកឲ្យ រុងរឿង ទប់សត្វមិនឲ្យធ្លាក់ទៅកាន់ទីទាប ៗ

អាត្មាភាពសំដែងមកអំពីដើមកំណើតនៃសេចក្តីសុខ សូមសន្មតថា ចប់ដោយសង្ខេបតែប៉ុណ្ណោះ ឯវំ ៗ